OFFICE of the INSURANCE COMMISSIONER WASHINGTON STATE

# សិទ្ធិ របស់អ្នក និងការការពារ ប្រឆាំងនឹង វិក្កយបត្រ វេជ្ជសាស្ត្រ ភ្ញាក់ផ្អើល និងវិក្កយបត្រលើស ប្រាក់ធានារ៉ាប់រង នៅក្នុងរដ្ឋ Washington

*មាន ប្រសិទ្ធភាព នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2025*

*នៅពេល អ្នក ទទួលការថែទាំ បន្ទាន់ ឬ ត្រូវ បាន ព្យាបាល ដោយ អ្នកផ្តល់សេវាកម្ម នៅខាងក្រៅ បណ្តាញ នៅតាម មន្ទីរ ពេទ្យ ក្នុង បណ្តាញ ឬ មជ្ឈមណ្ឌល វះកាត់អ្នកជំងឺអាចដើរបាន អ្នក ត្រូវ បាន ការពារ ពី ការចេញ វិក្កយបត្រ ភ្ញាក់ផ្អើល ឬ វិក្កយបត្រលើស ប្រាក់ធានារ៉ាប់រង។*

## តើអ្វីជា " វិក្កយបត្រលើស ប្រាក់ធានារ៉ាប់រង" (ពេលខ្លះហៅថា "ការចេញ វិក្កយបត្រ ភ្ញាក់ផ្អើល")?

នៅពេលអ្នកទៅជួបវេជ្ជបណ្ឌិត ឬអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងទៀត អ្នកអាច ជំពាក់ ការចំណាយ លើការបង់ប្រាក់ធានារ៉ាប់រងដោយខ្លួនឯង នូវចំនួនជាក់ដូចជា ប្រាក់បង់រួមគ្នា ប្រាក់ សហធានារ៉ាប់រង និង/ឬប្រាក់បង់មុនសិនមុនទទួលពីក្រុមហ៊ុនធានារ៉ាប់រង។ ការចំណាយទាំងនេះ ត្រូវគេហៅថា ការ ចែករំលែកការចំណាយ។ អ្នកអាចមានការ ចំណាយផ្សេងៗទៀត ឬត្រូវបង់វិក្កយបត្រទាំងមូល បើសិនអ្នកទៅជួបអ្នកផ្តល់សេវា ឬ ទៅមើលជំងឺ នៅ កន្លែង ថែទាំសុខភា ព ដែលមិននៅក្នុង បណ្តាញ គម្រោង សុខភាពរបស់អ្នក។

"ក្រៅបណ្តាញ" ពណ៌នាអំពីអ្នកផ្តល់សេវា និង មណ្ឌល ថែទាំសុខភាពនានា ដែលមិនទាន់ បានចុះ កិច្ចសន្យា ជាមួយ គម្រោង សុខភាព របស់អ្នក។ អ្នកផ្តល់សេវាក្រៅបណ្តាញ អាចនឹងត្រូវ អនុញ្ញាតឱ្យ ចេញវិក្កយបត្រទៅអ្នក សម្រាប់ ភាពខុសគ្នារវាង ទឹកប្រាក់ ដែល គម្រោងរបស់អ្នក បានយល់ព្រម ទូទាត់ និងទឹកប្រាក់ ពេញលេញ ដែល បាន គិតថ្លៃសេវា។ នេះត្រូវ គេហៅថា "វិក្កយបត្រលើស ប្រាក់ធានារ៉ាប់រង។" ចំនួនទឹកប្រាក់នេះទំនងជាច្រើន ជាងការចំណាយក្នុងបណ្តាញ សម្រាប់សេវាកម្មដូចគ្នា ហើយប្រហែលជា មិនរាប់បញ្ចូល ក្នុងដែន កំណត់នៃការបង់ប្រាក់ធានារ៉ាប់រងដោយខ្លួនឯង ប្រចាំឆ្នាំរបស់អ្នកទេ។

" វិក្កយបត្រ វេជ្ជសាស្ត្រ ភ្ញាក់ផ្អើល" គឺជាវិក្កយបត្រលើសប្រាក់ធានារ៉ាប់រង ដែលមិនបាន រំពឹងទុក។ វាអាច កើតឡើង នៅពេល មិនអាច គ្រប់គ្រងបាន ថានរណា ពាក់ព័ន្ធ នៅក្នុងការ ថែទាំ របស់ អ្នក —ដូចជា នៅពេល អ្នក ជិះ រថយន្ត សង្គ្រោះ បន្ទាន់, មានការ ព្យាបាល បន្ទាន់ ឬ នៅពេល អ្នក គ្រោង ពេល ទៅពិនិត្យជំងឺ នៅ កន្លែង ព្យាបាល នៅ ក្នុង បណ្តាញ ប៉ុន្តែ ត្រូវ បាន ព្យាបាល ដោយ អ្នកផ្តល់សេវាកម្ម នៅក្រៅបណ្តាញ ដោយ មិន បាន រំពឹងទុក។

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវ បាន តម្រូវ ឱ្យ ប្រាប់អ្នក តាមគេហទំព័រ របស់គេ ឬ ប្រសិនបើអ្នកសួរថា តើ អ្នកផ្តល់សេវាកម្ម មន្ទីរពេទ្យ និង កន្លែង ព្យាបាល មួយណា នៅក្នុង បណ្តាញ របស់ពួកគេ។ មន្ទីរពេទ្យ កន្លែងវះកាត់ អ្នកផ្តល់សេវាកម្ម អ្នកផ្តល់សេវាបន្ទាន់ផ្នែក សុខភាពអាកប្បកិរិយា និង អ្នកផ្តល់សេវា រថយន្ត សង្គ្រោះបន្ទាន់ ត្រូវតែប្រាប់អ្នក ថា តើបណ្តាញ អ្នកផ្តល់សេវាកម្ម មួយណា ដែល ចូលរួម នៅក្នុង គេហទំព័រ ឬ ប្រសិនបើអ្នកសួរ។

## អ្នកមាន ការការពារ ពីការចេញ វិក្កយបត្រលើសប្រាក់ធានារ៉ាប់រងសម្រាប់៖

### សេវាកម្ម សង្គ្រោះបន្ទាន់

ប្រសិនបើ អ្នក មានស្ថានភាព ដែលត្រូវ ព្យាបាលជាបន្ទាន់, ស្ថានភាព វិបល្លាសផ្នែកសុខភាព ផ្លូវចិត្ត ឬ ដោយសារ ការប្រើប្រាស់ សារធាតុ ហើយប្រើប្រាស់ សេវាកម្ម សង្គ្រោះ បន្ទាន់ ពី អ្នកផ្តល់សេវាកម្ម ឬ កន្លែង ផ្តល់សេវាកម្មក្រៅ បណ្តាញ នោះ អ្នកផ្តល់សេវាកម្ម ឬ កន្លែងផ្តល់សេវាកម្ម ភាគច្រើន អាច នឹង ចេញ វិក្កយបត្រទៅអ្នក នូវ ទឹកប្រាក់ ចែករំលែកគ្នាចំណាយ សម្រាប់ គម្រោង ក្នុង បណ្តាញ (ដូចជា ការទូទាត់ប្រាក់រួមគ្នា ឬ ប្រាក់សហធានារ៉ាប់រង)។ អ្នកមិនអាចត្រូវគេ ចេញវិក្កយបត្រ លើសប្រាក់ធានារ៉ាប់រងសម្រាប់សេវាសង្គ្រោះបន្ទាន់ទាំងនេះបានទេ។ នេះ រួមទាំង ការ ដឹកជញ្ជូន សង្គ្រោះបន្ទាន់តាម រថយន្ត ឬ យន្តហោះ និង ការ ថែទាំ ដែល អ្នក ទទួល នៅក្នុង មន្ទីរ ពេទ្យ ឬ កន្លែង ព្យាបាល ដែល ផ្តល់សេវាកម្ម ពេលមានវិបត្តិ ដល់មនុស្ស ដែលជួប ភាព អាសន្ន ផ្នែក សុខភាព ផ្លូវចិត្ត ឬ វិបល្លាស ដោយសារ ការប្រើប្រាស់សារធាតុ។ អ្នកមិនអាចត្រូវគេ ចេញវិក្កយបត្រ លើសប្រាក់ធានារ៉ាប់រងសម្រាប់សេវាសង្គ្រោះបន្ទាន់ទាំងនេះបានទេ រួមទាំង សេវាកម្ម ដែល អ្នក អាច នឹង ទទួល នៅក្រោយ ពេល អ្នកមានស្ថានភាព នឹងនរ វិញ។

## សេវាកម្ម មួយចំនួន នៅក្នុង មន្ទីរពេទ្យ ក្នុង បណ្ដាញ ឬ មជ្ឈមណ្ឌល វះកាត់អ្នកជំងឺអាចដើរបាន

នៅពេលអ្នក ទទួលបានសេវាពីមន្ទីរពេទ្យ ក្នុងបណ្ដាញ ឬមជ្ឈមណ្ឌលវះកាត់ វះកាត់ អ្នកជំងឺអាចដើរបាន អ្នកផ្ដល់ សេវាមួយ ចំនួន អាចស្ថិតនៅ ក្រៅបណ្ដាញ។ ក្នុងករណីទាំងនេះ អ្នក ផ្ដល់សេវាកម្ម ទាំងនេះ ភាគច្រើន អាច ចេញ វិក្កយបត្រ មកអ្នក នូវ ទឹកប្រាក់ រួមគ្នា ចំណាយ នៅក្នុង គម្រោង ក្នុង បណ្ដាញ របស់អ្នក។

**អ្នកក៏មិនត្រូវបានតម្រូវឱ្យ ទទួលយកការថែទាំ ក្រៅបណ្ដាញផងដែរ។ អ្នកអាចជ្រើសរើស អ្នកផ្ដល់សេវា ឬមណ្ឌលថែទាំសុខភាពនៅក្នុង បណ្ដាញនៃគម្រោងរបស់អ្នកបាន។**

## តើនៅពេលណា ដែលអ្នកអាច ត្រូវ បាន សួរឱ្យ លះបង់ចោល ការការពារ របស់អ្នក ពី ការ ចេញ វិក្កយបត្រ លើស ប្រាក់ធានារ៉ាប់រង៖

អ្នកផ្ដល់សេវាថែទាំ សុខភាព រួមទាំង មន្ទីរពេទ្យ អ្នកផ្ដល់ សេវាកម្ម សុខភាព អាកប្បកិរិយាបន្ទាន់ និង អ្នកផ្ដល់សេវាកម្ម ដឹកជញ្ជូន សង្គ្រោះបន្ទាន់ តាម រថយន្ត ឬ តាម យន្តហោះ **<u>មិនអាច</u>** ទាមទារ ឱ្យ អ្នក លះបង់ ការការពារ របស់អ្នក ពី ការ ចេញ វិក្កយបត្រលើស ប្រាក់ធានារ៉ាប់រងបានទេ។

ប្រសិនបើអ្នកមាន ការធានារ៉ាប់រង តាមរយៈ គម្រោង សុខភាព ក្រុម ដែល ផ្ដល់ ថវិកា ដោយ ខ្លួនឯង នៅក្នុងស្ថានភាព តិចតួច អ្នកផ្ដល់សេវាកម្ម អាច សួរ អ្នក ឱ្យ ផ្ដល់ការ យល់ព្រម លះបង់ ការការពារ ផ្នែក ការ ចេញ វិក្កយបត្រលើស ប្រាក់ធានារ៉ាប់រង ប៉ុន្តែ អ្នក **<u>មិនអាច</u>** ត្រូវបានគេទាមទារ ឱ្យ ផ្ដល់ការយល់ព្រមទេ។ សូមទាក់ទងនិយោជក ឬគម្រោងសុខភាពរបស់អ្នក សម្រាប់ព័ត៌មានបន្ថែម។

## នៅពេលដែល មិនមានការអនុញ្ញា តឱ្យ ចេញ វិក្កយបត្រលើស ប្រាក់ធានារ៉ាប់រង អ្នកក៏មានការការពារ ដូចខាងក្រោម៖

- អ្នកទទួលខុសត្រូវតែលើការចែករំលែកលើចំណែក របស់អ្នកប៉ុណ្ណោះ (ដូចជាប្រាក់ ទូទាត់រួមគ្នា ប្រាក់សហ ធានារ៉ាប់រង និងប្រាក់បង់មុនសិនមុនទទួលពីក្រុមហ៊ុនធានារ៉ាប់រង ប្រសិនបើអ្នកផ្ដល់សេវា ឬមណ្ឌលថែទាំ សុខភាព នោះនៅ ក្នុងបណ្ដាញ)។ គម្រោង សុខភាពរបស់អ្នក នឹងទូទាត់ឱ្យអ្នកផ្ដល់សេវា និងមណ្ឌលថែទាំសុខភាពក្រៅបណ្ដាញដោយផ្ទាល់។
- គម្រោង ថែទាំសុខភាព របស់អ្នក ជាទូទៅ ត្រូវតែ៖
    - ធានារ៉ាប់រង លើសេវាសង្គ្រោះបន្ទាន់ដោយ មិនតម្រូវឱ្យអ្នកយល់ព្រមលើសេវានានាជាមុន (ការអនុញ្ញាតជាមុន) ទេ។
    - ធានារ៉ាប់រងលើ សេវាសង្គ្រោះបន្ទាន់ពីអ្នកផ្ដល់សេវាក្រៅបណ្ដាញ។
    - ផ្អែកលើអ្វីដែលអ្នកជំពាក់ អ្នកផ្ដល់សេវា ឬមណ្ឌល (ការចែករំលែកថ្លៃចំណាយ) លើអ្វីដែលអ្នកផ្ដល់សេវាក្នុងបណ្ដាញ ឬមណ្ឌល និងបង្ហាញចំនួននោះនៅក្នុងការ ពន្យល់អំពីអត្ថប្រយោជន៍របស់អ្នក។
    - រាប់ចំនួនដែលអ្នកត្រូវបង់លើសេវាសង្គ្រោះបន្ទាន់ ឬសេវាក្រៅបណ្ដាញចំពោះចំនួនកំណត់នៃទឹកប្រាក់កាត់កង និងការបង់ប្រាក់ធានារ៉ាប់រងដោយខ្លួនឯងរបស់អ្នក។

**ប្រសិនបើអ្នកជឿថា អ្នកត្រូវ បាន ចេញ វិក្កយបត្រ ដោយ ច្រលំ** អ្នកអាច ប្ដឹងទៅ រដ្ឋាភិបាល សហព័ន្ធ តាម https://www.cms.gov/nosurprises/consumers ឬ ដោយ ហៅទៅលេខ 1-800-985-3059; និង/ឬ ប្ដឹងទៅការិយាល័យ ស្នងការ ធានារ៉ាប់រងរដ្ឋ Washington តាម គេហទំព័រ របស់គេ ឬ ដោយការហៅទៅលេខ 1-800-562- 6900។

ចូលមើល https://www.cms.gov/nosurprises សម្រាប់ព័ត៌មាន បន្ថែម អំពី សិទ្ធិ របស់អ្នក នៅក្រោម ច្បាប់សហព័ន្ធ។

ចូលមើល គេហទំព័ រ របស់ ការិយាល័យ ស្នងការ ធានារ៉ាប់រងរដ្ឋ Washington សម្រាប់ ព័ត៌មាន បន្ថែម អំពី សិទ្ធិ របស់អ្នក នៅក្រោម ច្បាប់ របស់ រដ្ឋ Washington ។